# សេចក្តីប្រកាសព័ត៌មាន

## ការប្រកាសលទ្ធផលនៃបេក្ខជនជ័យលាភីក្នុងការប្រកួតប្រជែងបង្កើតឡូហ្គោចូលរួមក្នុង “ព្រឹត្តិការណ៍គីហ្សូណាជប៉ុន-កម្ពុជា”

*ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤*

ដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍គីហ្សូណាជប៉ុន-កម្ពុជា ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជាមានសេចក្តីសោមនស្សរីករាយសូមប្រកាសនូវបេក្ខជនជ័យលាភីសម្រាប់ការប្រកួតប្រជែងបង្កើតឡូហ្គោក្នុងព្រឹត្តិការណ៍គីហ្សូណាជប៉ុន-កម្ពុជាដូចខាងក្រោម៖

| | |
|---|---|
| **ឈ្មោះ** | **កញ្ញា ប៊ូ ពុទ្ធីដា** |
| **សញ្ជាតិ** | **ខ្មែរ** |
| **ឡូហ្គោ** | |
| **អត្ថន័យនៃឡូហ្គោ** | ឡូហ្គោនេះគឺពិពណ៌នាអំពីកូនក្រមុំពីររូបក្នុងសម្លៀកបំពាក់ប្រពៃណីជប៉ុនគីម៉ូណូដែលតំណាងអោយប្រទេសជប៉ុន និងសម្លៀកបំពាក់ប្រពៃណីខ្មែរអប្សរាតំណាងអោយប្រទេសកម្ពុជា ព្រមទាំងមានបង់កក្រមាខ្មែរ ស្ថិតនៅក្រោមផ្លិតប្រពៃណីជប៉ុនដូចគ្នា ដែលរូបនេះបង្ហាញអោយឃើញនូវគុណតម្លៃ និងការចែករំលែកវប្បធម៌រវាងជប៉ុននិងកម្ពុជា។ ការបញ្ចូលនូវទង់ជាតិទាំងពីររួមគ្នាគឺជានិម្មិតរូបនៃមិត្តភាពដ៏យូរអង្វែងរវាងប្រទេសទាំងពីរ។ ចំពោះឃ្លាដែលមានអត្ថន័យថាព្រឹត្តិការណ៍គីហ្សូណាជាអក្សរព័ណ៌ខៀវរាងកោងខាងក្រោមគឺតំណាងអោយភាពជឿជាក់និងភាពស្មោះត្រង់រវាងគ្នាទៅវិញទៅមក។ |

ស្ថានទូតមានសេចក្តីសោមនស្សរីករាយចំពោះការដាក់ពាក្យចូលរួមរបស់បេក្ខជនជាច្រើនក្នុងការប្រកួតប្រជែងបង្កើតឡូហ្គោ។

ក្នុងព្រឹត្តិការណ៍នេះ មានកម្មវិធីផ្សេងៗនឹងត្រូវបានរៀបចំក្នុងគោលបំណងជម្រុញនូវមិត្តភាពនិងការផ្លាស់ប្តូររវាងមនុស្សនិងមនុស្សក្នុងវិស័យសេដ្ឋកិច្ច វប្បធម៌ សិល្បៈ វិទ្យាសាស្ត្រ កីឡា និងទេសចរណ៍។ ឡូហ្គោនេះនឹងត្រូវបានប្រើប្រាស់ជាផ្លូវការនៅក្នុងកម្មវិធីដែលបានបញ្ចូលទៅក្នុងព្រឹត្តិការណ៍គីហ្សូណាជប៉ុន-កម្ពុជា។

---

**Embassy of Japan, No. 194 Preah Norodom Blvd, Tel: (023) 217-161/4, Fax: (023) 216 162, Email: info.jpn@pp.mofa.go.jp,**
**Official Website: www.kh.emb-japan.go.jp**